Chham Chhany 1 hr ·

# រឿងពិតពាក់ព័ន្ធនឹងការបញ្ចប់កិច្ចសន្យាប្រមូលចំណូលលក់ប័ណ្ណទស្សនាអង្គរវត្ត គឺកើតចេញពីការស្នើសុំរបស់ក្រុមហ៊ុនសុខា អូតែល

Posted by DTN7 on November 6, 2015

មជ្ឈដ្ឋានប្រជាពលរដ្ឋជាច្រើនបានសម្តែងនូវការអបអរសាទរចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ បញ្ចប់កិច្ចសន្យាស្តីពីការប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនាប្រាសាទអង្គរវត្ត ជាមួយក្រុមហ៊ុនសុខា អូតែល របស់លោកឧកញ៉ា សុខ គង់ ហើយរាជរដ្ឋាភិបាលចាត់ចែងធ្វើការគ្រប់គ្រងដោយផ្ទាល់វិញ ក្រោមរូបភាពសហគ្រាសសាធារណៈ គ្រោងនឹងចាប់ផ្តើមដំណើរការនៅដើមខែមករា ឆ្នាំ២០១៦ខាងមុខ ។

ជាមួយនឹងការសម្រេចចិត្តខាងលើនេះ មជ្ឈដ្ឋាននានាគិតស្មានថា កើតចេញពីការផ្តួចផ្តើមគំនិតរបស់រាជរដ្ឋាភិបាល ប៉ុន្តែតាមការពិតក្នុងរឿងបញ្ចប់កិច្ចសន្យាស្តីពីការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាអង្គរ រវាងអាជ្ញាធរអប្សរាជាមួយក្រុមហ៊ុនសុខា អូតែល របស់លោកឧកញ៉ា សុខ គង់ គឺកើតចេញពីសំណើរបស់ក្រុមហ៊ុនសុខា អូតែល ទៅវិញទេ ។ មានន័យថា ក្រុមហ៊ុនប្រមូលលុយយ៉ាងកាក់កបអស់ជាច្រើនឆ្នាំមកហើយ ក្នុងការធ្វើសកម្មប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាប្រាង្គប្រាសាទអង្គរវត្ត ទើបក្រុមហ៊ុនសុខា អូតែល របស់លោកឧកញ៉ា សុខ គង់ ស្នើសុំរាជរដ្ឋាភិបាលជាភាគីនៃកិច្ចសន្យាបញ្ចប់កិច្ចសន្យាតែម្តង ។

នៅពេលសហគ្រាសសាធារណៈបង្កើតឡើងសម្រាប់ដំណើរការគ្រប់គ្រង និងប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនាប្រាសាទអង្គរវត្តរួចរាល់ គឺបុគ្គលិកទាំងអស់របស់ក្រុមហ៊ុនសុខា អូតែល ដែលកំពុងបម្រើការងារផ្នែកប្រមូលចំណូល នឹងបន្តការងាររបស់ខ្លួនដដែល ក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈនេះ ។

សូមបញ្ជាក់ជូនថា តួលេខចំណូលដុលរយៈពេល៦ឆ្នាំជាប់ៗគ្នាប្រកាសដោយអាជ្ញាធរអប្សរា បានមកពីការធ្វើសេវាកម្មប្រមូលចំណូលពីការលក់ប័ណ្ណចូលទស្សនាប្រាសាទអង្គរវត្ត គ្រប់គ្រងដោយក្រុមហ៊ុនសុខា អូតែល របស់លោកឧកញ៉ា សុខ គង់ កើតចេញពីកិច្ចសន្យាសម្បទាន(មិនឆ្លងកាត់ការដេញថ្លៃសាធារណៈ)រវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុនសុខា អូតែល នោះ មានដូចខាងក្រោម ៖

-ឆ្នាំ២០១០ ចំនួន ៣៣.១១៣.៥០០ ដុល្លារអាមេរិក

-ឆ្នាំ២០១១ ចំនួន ៤២.១៨៥.៣០០ ដុល្លារអាមេរិក

-ឆ្នាំ២០១២ ចំនួន ៥១.៣១៩.១៨០ ដុល្លារអាមេរិក

-ឆ្នាំ២០១៣ ចំនួន ៥៧.៦៨៧.៦៨០ ដុល្លារអាមេរិក

-ឆ្នាំ២០១៤ ចំនួន ៥៩.៣៤២.០០០ ដុល្លារអាមេរិក

-ឆ្នាំ២០១៥ (រយៈពេល១០ខែ) ចំនួន ៤៧.៦៨១.០៨០ ដុល្លារអាមេរិក ៕